**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងរដ្ឋប្បវេណីលេខ: ២៣៧
ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២
សាលក្រមរដ្ឋប្បវេណីលេខ: ០៣ (គ)
ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃពុធ ០៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រម**

លោក [redacted] អនុប្រធាន និងជាចៅក្រមនៃសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

**ដើមចោទ** ឈ្មោះ [redacted] **ភារិត** ភេទស្រី កើតឆ្នាំ១៩៩១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីលំនៅបច្ចុប្បន្ន[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ស្រ៊ុ (រស់) ម្ដាយឈ្មោះ [redacted]អ៊ុម (រស់) ប្ដីឈ្មោះ [redacted]ចាន់ធី មានកូន១នាក់។

ដោយមាន លោក [redacted] អត្តលេខ ៦១៣ និងលោក [redacted] អត្តលេខ ២៥៦៣T ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បម្រើការងារ នៅការិយាល័យមេធាវី [redacted] ដែលមានអាសយដ្ឋានផ្ទះ [redacted]។

**ចុងចម្លើយ** ឈ្មោះ [redacted] **ចាន់ធី** ភេទប្រុស កើតឆ្នាំ១៩៩៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន[redacted] ឪពុកឈ្មោះ [redacted] ឈឿន (រស់) ម្ដាយឈ្មោះ [redacted]ស៊ីណាត (រស់) ប្រពន្ធឈ្មោះ [redacted]ភារិត មានកូន១នាក់។

**អង្គហេតុ និងចំណុចវិវាទ**

**១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖**

ក-សុំលែងលះប្ដីឈ្មោះ [redacted] ចាន់ធី។

ខ-សុំសិទ្ធិគ្រប់គ្រងកូនចំនួន ១នាក់។

**២-ការពន្យល់ត្រួសៗអំពីអង្គហេតុ៖**

ដើមចោទឈ្មោះ [redacted] **ភារិត** បានរៀបអាពាហ៍ពិពាហ៍ជាមួយប្ដីឈ្មោះ [redacted] **ចាន់ធី** និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ក្នុងចំណងអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយ មានកូនចំនួន ១នាក់ ឈ្មោះ [redacted] **សិរីវត្ត** ភេទស្រី កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១។ បន្ទាប់ពីរៀបការ



Scanned with CamScanner

រួចដើមចោទ និងចុងចម្លើយ រស់នៅមិនចុះសម្រុងនឹង គ្នានោះទេ គឺតែងតែមានទំនាស់ពាក្យសំដី និងរកាំរកូសនឹងគ្នា ដែលនាំឱ្យដើមចោទអស់ មនោសញ្ចេតនា រស់នៅជាប្ដីប្រពន្ធតទៅទៀត។ ទើបដើមចោទដាក់ពាក្យបណ្ដឹងលែងលះនេះតែម្ដង។

**៣-ការអះអាងរបស់ភាគី៖**

**៣.១ សេចក្ដីថ្លែងការណ៍របស់ដើមចោទឈ្មោះ[redacted]ភារិត។**

ដើមចោទឈ្មោះ [redacted] **ភារិត** ធ្វើសេចក្ដីថ្លែងការណ៍ដោយសុំឱ្យតុលាការ ចេញសាលក្រមដូចខាងក្រោមនេះ៖

ក-សុំលែងលះប្ដីឈ្មោះ ឈឿង ចាន់ធី។

ខ-សុំសិទ្ធិគ្រប់គ្រងកូនចំនួន ១នាក់។

នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយប្ដីឈ្មោះ [redacted] **ចាន់ធី** និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ក្នុងចំណងអាពាហ៍ពិពាហ៍បាននាងខ្ញុំមានកូនចំនួន ១នាក់ ឈ្មោះ [redacted] **សិរីវត្ត** ភេទស្រី កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ នាងខ្ញុំសុំទាមទារសិទ្ធិអំណាចមេបា ដោយសារកូននៅតូចហើយកូនរស់នៅជាមួយខ្ញុំរហូត។ បន្ទាប់ពីរៀបការរួចនាងខ្ញុំនិងប្ដី រស់នៅមិនចុះសម្រុងនឹង គ្នានោះទេ គឺតែងតែមានទំនាស់ពាក្យសំដី និង រកាំរកូសនឹងគ្នា ដែលនាំឱ្យនាងខ្ញុំអស់ មនោសញ្ចេតនារស់នៅជាប្ដីប្រពន្ធតទៅទៀត។ ទើបនាងខ្ញុំដាក់ពាក្យបណ្ដឹងលែងលះនេះតែម្ដង។

**៣.២ សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ[redacted]ភារិត។**

លោក [redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្ដីថ្លែងការណ៍៖ ខ្លួនឯកភាពតាមសេចក្ដីថ្លែងការណ៍របស់កូនក្ដីខ្លួន។

លោក [redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្ដីថ្លែងការណ៍៖ ខ្លួនឯកភាពតាមសេចក្ដីថ្លែងការណ៍របស់កូនក្ដីខ្លួន។

**៣.៣ សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ[redacted] ចាន់ធី។**

ចុងចម្លើយឈ្មោះ [redacted] **ចាន់ធី** ធ្វើសេចក្ដីថ្លែងការណ៍ ខ្ញុំបាទយល់ព្រមលែងលះ ជាមួយប្រពន្ធឈ្មោះ [redacted] **ភារិត** ព្រោះពួកខ្ញុំរស់នៅមិនចុះសម្រុងនឹងគ្នាប្រាកដមែន ចំណែកកូនឈ្មោះ[redacted] **សិរីវត្ត** ភេទស្រី កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ខ្ញុំបាទយល់ព្រមប្រគល់សិទ្ធិអំណាចមេបា ឱ្យដើមចោទ ប៉ុន្តែខ្ញុំបាទសុំសិទ្ធិចូលប្រាស្រ័យទាក់ទងកូន។

**៤-ភស្តុតាង**

**បានឃើញ** សំបុត្រអាពាហ៍ពិពាហ៍លេខ២៤ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ សៀវភៅអាពាហ៍ពិពាហ៍ លេខ ០១/២០២០ ។

**បានឃើញ** សំបុត្រកំណើតលេខ២៨ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ សៀវភៅកំណើតលេខ ០១/២០២១ របស់ឈ្មោះ[redacted]សិរីវត្ត។

**៥-ចំណុចគ្មានវិវាទ និងចំណុចមានវិវាទ**

**៥.១.ចំណុចគ្មានវិវាទ មានដូចខាងក្រោម៖**

ក-ដើមចោទ និងចុងចម្លើយ ព្រមព្រៀងគ្នាលែងលះ។

ខ-ដើមចោទ និងចុងចម្លើយ ព្រមព្រៀងគ្នាប្រគល់សិទ្ធិអំណាចមេបាលើកូនមួយនាក់ឈ្មោះ [redacted] សិរីវត្ត ភេទស្រី កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ឱ្យដើមចោទជាអ្នកមានសិទ្ធិអំណាចមេបា។

៥.២.ចំណុចមានវិវាទ (គ្មាន)

## សំអាងហេតុ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ រួចមកឃើញថា៖

១-តាមសំបុត្រអាពាហ៍ពិពាហ៍លេខ២៤ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០២០ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ ឃើញថា ដើមចោទឈ្មោះ [redacted] **ភារិត** និងចុងចម្លើយឈ្មោះ [redacted] **ចាន់ធី** គឺជាសហព័ទ្ធ ត្រឹមត្រូវស្របតាម ច្បាប់ប្រាកដមែន និងតាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] **ភារិត** និងចុងចម្លើយឈ្មោះ [redacted] **ចាន់ធី** បានព្រមព្រៀងគ្នាលែងលះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងនេះ តាមមាត្រា **៩៧៩** នៃក្រមរដ្ឋប្បវេណី។

២-តាមសំបុត្រកំណើត លេខ២៨ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ សៀវភៅកំណើតលេខ ០១/២០២១ របស់ឈ្មោះ [redacted] **សិរីវត្ត** ឃើញថា ឈ្មោះ [redacted] **សិរីវត្ត** ពិតជាកូនរបស់ដើមចោទឈ្មោះ [redacted] **ភារិត** និងចុងចម្លើយឈ្មោះ [redacted] **ចាន់ធី** ប្រាកដមែន ហើយដើមចោទឈ្មោះ [redacted] **ភារិត** និងចុងចម្លើយឈ្មោះ [redacted] **ចាន់ធី** បានព្រមព្រៀងគ្នាប្រគល់កូនមួយនាក់ខាងលើ ឱ្យដើមចោទឈ្មោះ [redacted] **ភារិត** ជាអ្នកមានសិទ្ធិអំណាចមេបា គប្បីតុលាការសម្រេចតាមការព្រមព្រៀងនេះ តាមមាត្រា **១០៣៧** កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៣-ប្រាក់ប្រដាប់ក្តីមិនមានភាគីណាស្នើសុំទទួលបន្ទុក គប្បីតុលាការសម្រេចតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ឱ្យដើមចោទឈ្មោះ [redacted] **ភារិត** លែងលះពីចុងចម្លើយឈ្មោះ [redacted] **ចាន់ធី** លើសំបុត្រអាពាហ៍ពិពាហ៍លេខ២៤ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ សៀវភៅអាពាហ៍ពិពាហ៍ លេខ ០១/២០២០ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ។

២-ឱ្យដើមចោទឈ្មោះ [redacted] **ភារិត** ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] **សិរីវត្ត** ភេទស្រី កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ចំពោះចុងចម្លើយឈ្មោះ [redacted] **ចាន់ធី** ដែលគ្មានសិទ្ធិអំណាចមេបា មានសិទ្ធិចូលប្រាស្រ័យទាក់ទងកូនបាន ហើយដើមចោទឈ្មោះ [redacted] **ភារិត** ត្រូវបង្កលក្ខណៈងាយស្រួលក្នុងការចូលប្រាស្រ័យទាក់ទងនេះ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ ៥០% និង ចុងចម្លើយ ៥០%។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃពុធ ០៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខដើមចោទឈ្មោះ [redacted] **ភារិត** និងចុងចម្លើយឈ្មោះ [redacted] **ចាន់ធី**។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅតាកែវ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣

**ចៅក្រម**

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅតាកែវ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]